**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា**
**ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ**

# សេចក្តីជូនដំណឹង

គណៈកម្មការផ្តល់ភាពស្របច្បាប់ ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅនិងធ្វើការនៅប្រទេសថៃ សូមជូនដំណឹងដល់សាធារណជន ជាពិសេសបងប្អូនពលករកម្ពុជា ដែលបានបញ្ជាក់អត្តសញ្ញាណ ធ្វើលិខិតឆ្លងដែន/លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស និងប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស (OCWC) ជាមួយគណៈកម្មការ ជ្រាបថា នាម៉ោង ២:៣០នាទីរសៀល ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៧នេះ នៅទីស្តីការក្រសួងការងារថៃ ឯកឧត្តម **ហ៊ុន ម៉ាណែត** អនុប្រធានគណៈកម្មការផ្តល់ភាពស្របច្បាប់បានដឹកនាំប្រតិភូកម្ពុជាចូលជួបពិភាក្សាការងារជាមួយ ឯកឧត្តម **ស៊ីរិឆៃ ឌីស្តាគុល** (**Sirichai Distakul**) រដ្ឋមន្ត្រីក្រសួងការងារថៃ ដើម្បីស្នើសុំភាគីថៃសហការបង្កើនចំនួនការិយាល័យបើកផ្តល់ និងលទ្ធភាពបង្កើនល្បឿនបើកផ្តល់ លិខិតឆ្លងដែន/លិខិតធ្វើដំណើរ និងប័ណ្ណ OCWC ជូនដល់ពលករកម្ពុជា។ កិច្ចប្រជុំនេះបានប្រព្រឹត្តទៅក្រោមបរិយាកាសយោគយល់ ស្និទ្ធស្នាល និងទទួលបានលទ្ធផលជាវិជ្ជមានដូចខាងក្រោម៖

១. ភាគីថៃបានឯកភាពអនុញ្ញាតឲ្យគណៈកម្មការផ្តល់ភាពស្របច្បាប់របស់កម្ពុជា ចុះធ្វើការបើកផ្តល់លិខិតឆ្លងដែន/លិខិតធ្វើដំណើរ និងប័ណ្ណ OCWC ជូនដល់ពលករកម្ពុជាដោយផ្ទាល់នៅតាមរោងចក្រ សហគ្រាសថៃទាំងឡាយណា ដែលមានប្រើប្រាស់ពលករកម្ពុជាចាប់ពី៨០នាក់ឡើង។

២. បន្ថែមពីលើការិយាល័យបើកផ្តល់ ដែលមានស្រាប់នៅក្នុងស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំទីក្រុងបាងកក និងប្រព័ន្ធអនឡាញ (www.cambodianworker.net) ភាគីថៃបានឯកភាពអនុញ្ញាតឲ្យកម្ពុជាបើកការិយាល័យបើកផ្តល់ចំនួន ៥កន្លែងបន្ថែមទៀត ដែលមានទីតាំងស្ថិតនៅក្នុងខេត្តសាមុត្រប្រាកាន ឈុនបុរី ប៉ាធុមថានី ឆាក់ឈើងសាវ និងរ៉ាក់យ៉ង។ ភាគីថៃនឹងជូនដំណឹងដល់កម្ពុជានូវទីតាំងទាំង៥កន្លែងថ្មីនោះ។

៣. ភាគីថៃនឹងអនុញ្ញាតដល់ភាគីកម្ពុជាចាប់ផ្តើមចុះប្រមូលទិន្នន័យ និងបញ្ជាក់សញ្ជាតិដល់ពលករកម្ពុជា ដែលមានប័ណ្ណព័ណ៌ស៊ីជំពូឡើងវិញ ក្រោយពេលដែលការិយាល័យបើកផ្តល់ថ្មីទាំង៥កន្លែងនេះដំណើរការទៅដោយរលូន។

៤. ការិយាល័យអន្តោប្រវេសន៍ថៃនៅគ្រប់ទីតាំងនឹងផ្តល់ទិដ្ឋាការស្នាក់នៅដល់ពលករកម្ពុជាទាំងឡាយណា ដែលមានប័ណ្ណព័ណ៌ស៊ីជំពូដែលនៅមានសុពលភាព និងទទួលបានលិខិតឆ្លងដែន/លិខិតធ្វើដំណើរ និងប័ណ្ណ OCWC ពីគណៈកម្មការផ្តល់ភាពស្របច្បាប់របស់កម្ពុជា។

៥. ភាគីទាំង២បានបង្កើតក្រុមការងារចំពោះកិច្ច១ដើម្បីរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តនូវស្មារតីកិច្ចប្រជុំនាថ្ងៃទី៦ ខែកុម្ភៈ នេះ។ ភាគីទាំង២បានកំណត់ពេលវេលាយ៉ាងយូរ១៥ថ្ងៃ ដល់ក្រុមការងារចំពោះកិច្ចនេះ ដើម្បីដាក់ចេញនូវផែនការសកម្មភាពសម្រាប់អនុវត្ត។

៦. ភាគីថៃបានសម្តែងនូវការសាទរចំពោះភាគីកម្ពុជា ដែលបានបន្ថែមថ្ងៃបម្រើសេវាជូនពលករចំនួន ១ថ្ងៃបន្ថែមទៀតក្នុង១សប្តាហ៍ ពោលគឺធ្វើការទាំងថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ ដោយឈប់សម្រាកនាថ្ងៃសុក្រវិញ ព្រមទាំងបានបន្ថែម៉ោងបម្រើសេវាជូនពលករចំនួន ១ម៉ោង បន្ថែមទៀតក្នុង១ថ្ងៃ ពោលគឺធ្វើការចាប់ពីម៉ោង៨:៣០នាទីព្រឹក ដល់ម៉ោង៦:៣០នាទីយប់ ដោយឈប់សម្រាកអាហារថ្ងៃត្រង់ត្រឹម១ម៉ោងប៉ុណ្ណោះ។

អាស្រ័យន័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន ជាពិសេសពលករកម្ពុជាដែលកំពុងស្នាក់នៅនិងធ្វើការនៅប្រទេសថៃជ្រាបជាព័ត៌មាន។

*រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៧*